ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០៤ ករណីថ្មីទៀត ជាជនបរទេសដែលជាអ្នកដំណើរតាមនាវា Viking Cruise Journey និង អ្នកជាសះស្បើយ ០៤ ករណី ជាជនជាតិខ្មែរ

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ វេលាយប់ម៉ោង ២០:៣០នាទី បានបង្ហាញនូវលទ្ធផលវិភាគវត្ថុសំណាកពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ចំនួន ០៤នាក់ វិជ្ជមានវីរុសកូវីដ១៩ ថ្មីទៀត និងអ្នកជាសះស្បើយ ចំនួន ០៤ នាក់ ដែលមានដូចខាងក្រោម៖

**១. នៅខេត្តកំពង់ចាម៖ ០៤ ករណី (ជនជាតិអង់គ្លេស ០២នាក់ និងជនជាតិអាមេរិកាំង ០២នាក់)**

- ជនជាតិអង់គ្លេស៖ បុរសអាយុ ៦១ឆ្នាំ និងស្ត្រីអាយុ ៧៩ឆ្នាំ វិជ្ជមានវីរុសកូវីដ១៩
- ជនជាតិអាមេរិកាំង៖ ប្តីអាយុ ៥៩ឆ្នាំ និងប្រពន្ធអាយុ ៦២ឆ្នាំ វិជ្ជមានកូវីដ១៩

សម្គាល់៖ ពួកគាត់ទាំង៤នាក់ ជាអ្នកដែលនៅក្នុងចំណោមអ្នកដំណើរតាមនាវា Viking Cruise Journey ដែលបានដាក់ឲ្យនៅដាច់ដោយឡែកចំនួន ១៤ថ្ងៃ ហើយត្រូវបានរកឃើញថាមានវីរុសកូវីដ១៩ នៅវេលាយប់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ហើយពួកគាត់ត្រូវបានដាក់ឲ្យនៅសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។ រីឯអ្នកដំណើរចំនួន ៥៣នាក់ ផ្សេងទៀតនៅក្នុងចំនួន ៥៧នាក់ ដែលបានដាក់ឲ្យនៅដាច់ដោយឡែកចំនួន ១៤ថ្ងៃនោះ មានលទ្ធផលតេស្តអវិជ្ជមាន។ ពួកគាត់ទាំង ៥៣នាក់ នេះ នឹងត្រូវឲ្យចាកចេញពីសណ្ឋាគារមួយនៅក្នុងខេត្តកំពង់ចាម។

**២. នៅខេត្តត្បូងឃ្មុំ៖ ០២ ករណីជាសះស្បើយ ជាជនជាតិខ្មែរ**

បុរសអាយុ ៦១ឆ្នាំ និងបុរសអាយុ ៥៣ឆ្នាំ ដែលមានវីរុសកូវីដ១៩ មានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន០២លើក ហើយត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តត្បូងឃ្មុំនៅថ្ងៃនេះរួចហើយ។

**៣. នៅខេត្តបាត់ដំបង៖ ០២ ករណីជាសះស្បើយ ជាជនជាតិខ្មែរ**

បុរសអាយុ ៨១ឆ្នាំ និងបុរសអាយុ ៤២ឆ្នាំ ដែលមានវីរុសកូវីដ១៩ ឥឡូវនេះ មានលទ្ធផលអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ហើយត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**៤. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង២១:៣០ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន **៩១ នាក់ (ស្រី ២៤នាក់ ប្រុស ៦៧នាក់)** ដែលក្នុងនោះ មានអ្នកជាសះស្បើយចំនួន **០៦នាក់** (ជនជាតិចិន ០១នាក់ អង់គ្លេស ០១ នាក់ និងខ្មែរ ០៤នាក់) ។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន នៅរៀងរាល់យប់នៃថ្ងៃបន្ទាប់ពីថ្ងៃដែលបានចេញសេចក្តីជូនព័ត៌មាន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេស ប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ០១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០

ចំនួនករណីវិជ្ជមានកូវីដ ១៩ ថ្មីដែលបានរកឃើញប្រចាំថ្ងៃ




ប្រភពៈ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០

និន្នាការនៃចំនួនករណីវិជ្ជមានកូវីដ ១៩ ដែលបានរកឃើញ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពស្តីពីជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០

### ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត




**សរុប៖ ៩១ ករណី**

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០

### ភាគរយនៃករណីវិជ្ជមានកូវីដ ១៩ តាមជនជាតិ
### ក្នុងចំណោម ៩១ ករណីដែលបានរកឃើញ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០

### ករណីវិជ្ជមានកូវីដ ១៩ តាមភេទ
### ក្នុងចំណោម ៩១ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០

### ចំនួនករណីដែលបានជាសះស្បើយ និង
### ករណីដែលកំពុងព្យាបាល

**សរុប៖ ៩១ ករណី**




| | |
|---|---|
| ករណីកំពុងបិតក្នុងការព្យាបាល | ៨៥ |
| ករណីជាសះស្បើយ | ៦ |

ប្រភព៖ ក្រសួងសុខាភិបាល